# សុន្ទរកថា
## ឯកឧត្តមប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ
## និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារអាកាសចរស៊ីវិល
## ឆ្នាំ២០១៣-២០១៧ និងលើកទិសដៅសម្រាប់ឆ្នាំ២០១៨-២០២៣

ថ្ងៃព្រហស្បត្តិ៍ ៩ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ ២០១៨

- *ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា នៃរាជរដ្ឋាភិបាលកម្ពុជា ជាទីរាប់អាន!*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងស្ថាប័នពាក់ព័ន្ធ ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ សមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល ជាទីមេត្រី!*

១. ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានមកចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ ក្នុងពិធីបើក « **សន្និបាតបូកសរុបលទ្ធផលការងារអាកាសចរស៊ីវិលឆ្នាំ២០១៣-២០១៧ និងលើកទិសដៅសម្រាប់ឆ្នាំ២០១៨-២០២៣** » របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់មួយ សម្រាប់វិស័យវិស័យអាកាសចរស៊ីវិលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំសូមយកឱកាសនេះ ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានឆ្លៀតពេលដ៏មមាញឹកអញ្ជើញចូលរួមក្នុងពិធីនេះ ដែលញ៉ាំងឱ្យអង្គសន្និបាតទាំងមូលប្រព្រឹត្តទៅដោយភាពអធិកអធម ក្នុងបរិយាកាសរីករាយ។

២. ជាមួយគ្នានេះដែរ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលទាំងអស់ ដែលបានខិតខំយកអស់កម្លាំងកាយ ចិត្ត បញ្ញា និងស្មារតី ក្នុងការបំពេញតួនាទី ភារកិច្ច និងបេសកកម្មរបស់ខ្លួន ក្នុងបណ្តាឆ្នាំកន្លងទៅក្នុងបុព្វហេតុអភិវឌ្ឍន៍ប្រព័ន្ធអាកាសចរស៊ីវិលឲ្យមានសុវត្ថិភាព សន្តិសុខ ល្អប្រសើរ និងប្រសិទ្ធភាពខ្ពស់ ដើម្បីធ្វើជាកត្តាលីករដ៏សំខាន់សម្រាប់ការរីកលូតលាស់នៃសេដ្ឋកិច្ច និងសេវាកម្មរបស់ប្រទេសជាតិ ។

៣.	ដូច ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានបញ្ជាក់ជូនអម្បាញ់មិញហើយថា ការជួបជុំគ្នាថ្ងៃនេះមិនត្រឹមតែជាសក្ខីភាពបញ្ជាក់នូវការចូលរួមអបអរសាទរចំពោះសមិទ្ធផលនានា ដែលរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលសម្រេចបានក្នុងឆ្នាំ២០១៧ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាឱកាសសម្រាប់យើងទាំងអស់គ្នាចូលរួមពិនិត្យវាយតម្លៃវឌ្ឍនភាពការងារ ដែលសម្រេចបានក្នុងអំឡុងពេល៥ឆ្នាំ គិតចាប់តាំងពីដើមអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៥ និងលើកទិសដៅសម្រាប់ឆ្នាំ ២០១៨-២០២៣ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

៤.	ខ្ញុំសូមចូលរួមអបអរសាទរចំពោះសមិទ្ធផលសំខាន់ៗជាច្រើន ដែលរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលសម្រេចបានរហូតមកដល់ពេលនេះ ហើយខ្ញុំក៏សូមយកឱកាសដ៏ប្រពៃនេះ សម្តែងនូវការគាំទ្រ និងលើកទឹកចិត្តឱ្យថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃស្ថាប័ននេះ បន្តខិតខំបំពេញភារកិច្ចរបស់ខ្លួនឱ្យបានកាន់តែខ្លាំងក្លាថែមទៀត ដើម្បីទទួលបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀតជូនជាតិមាតុភូមិរបស់យើង។

៥.	ជាការពិត សមិទ្ធផលទាំងនេះ ប្រាកដជាមិនអាចកើតមានឡើងបានទេ ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែង គោលនយោបាយ និងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ជាក់ស្តែង គោលនយោបាយ **«ឈ្នះ ឈ្នះ»** របស់សម្តេចតេជោ បាននាំមកនូវឯកភាពជាតិ សុខសន្តិភាព និងស្ថិរភាពពេញផ្ទៃប្រទេស ដែលពុំធ្លាប់មានក្នុងរយៈកាលប្រមាណ៥០០ឆ្នាំចុងក្រោយ នៃប្រវត្តិសាស្ត្រដ៏យូរលង់របស់កម្ពុជា ហើយដែលសន្តិភាព និងស្ថិរភាពនយោបាយនេះ គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់ការអភិវឌ្ឍគ្រប់វិស័យ រួមទាំងវិស័យអាកាសចរណ៍ស៊ីវិល ផងដែរ។

៦. ម៉្យាងទៀត សន្និបាតរបស់យើងនាថ្ងៃនេះ ក៏បានប្រព្រឹត្តទៅចំពេលដែលប្រទេសជាតិយើងកំពុងស្ថិតនៅក្នុងសន្តិភាពពេញបរិបូណ៌ ហើយប្រជាពលរដ្ឋ និងប្រជាជាតិទាំងមូលក៏កំពុងទទួលបាននូវមនុញ្ញផលនៃសន្តិភាពនេះជាមួយរាជរដ្ឋាភិបាលដែរ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និបាតទាំងមូលជាទីមេត្រី!***

៧ .ដូចយើងទាំងអស់គ្នាបានដឹងស្រាប់ហើយថា ក្នុងរបបប្រល័យពូជសាសន៍ **ប៉ុល ពត** ហេដ្ឋារចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច និងរូបវន្តនានា ព្រមទាំងធនធានមនុស្ស ត្រូវបានបំផ្លិចបំផ្លាញដល់ឫសគល់វិស័យអាកាសចរស៊ីវិលរបស់យើង ក៏ត្រូវបានផ្អាកដំណើរការផងដែរនៅ

ពេលនោះ។ ក្រោយថ្ងៃរំដោះ ៧ មករា១៩៧៩ វិស័យអាកាសចរកម្ពុជា ត្រូវបានដាក់ឲ្យដំណើរការសាជាថ្មី ដោយផ្ដើមចេញពីស្ថានភាពដ៏លំបាកលំបិនបំផុត ឈានទៅមុខជាជំហានៗ និងរហូតមកដល់ពេលនេះ យើងបានឆ្លងកាត់ពីដំណាក់កាលរីកចម្រើនមួយ ទៅដំណាក់កាលរីកចម្រើនមួយទៀត ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទាំងទំហំប្រតិបត្តិការប្រកបដោយមោទនៈភាព ជាពិសេស គឺបន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយ «**បើកចំហរជើងមេឃ**» ដែលបាន និងកំពុងប្រែក្លាយប្រទេសកម្ពុជាទៅជាមជ្ឈមណ្ឌលអាកាសចរណ៍ និងទេសចរណ៍មួយដែលមានភាពទាក់ទាញក្នុងតំបន់ និងពិភពលោក។

៨ . ជាការពិតណាស់ក្រោមការដឹកនាំរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងតាមរយៈការដាក់ចេញនូវចក្ខុវិស័យវែងឆ្ងាយដ៏ត្រឹមត្រូវសម្រាប់ការអភិវឌ្ឍប្រទេសជាតិ រួមជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រប្រកបដោយភាពជាក់ស្ដែង ប្រាកដនិយម និងភាពម៉ឺងម៉ាត់ កម្ពុជាសម្រេចបាននូវសមិទ្ធផលល្អប្រសើរ ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនគួរឲ្យកត់សំគាល់។ ជាមួយនឹងសមិទ្ធផលនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានចាត់ទុកប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅតំបន់អាស៊ី ហើយ បានប្រសិទ្ធនាមប្រទេសកម្ពុជា ជា «**ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី**» ទៀតផង។ ក្នុងឆ្នាំ ២០១៦ កន្លងទៅ កម្ពុជារក្សាបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា ៧.០ % ដោយសារការងើបឡើងវិញនៃកំណើនក្នុងវិស័យកសិកម្ម បន្ទាប់ពីស្ទើរតែគ្មានកំណើនសោះក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ខណៈដែលកំណើនវិស័យឧស្សាហកម្ម និងសេវាកម្មមានភាពថមថយបន្តិច។

៩. ទោះបីជាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ សេដ្ឋកិច្ចពិភពលោកកំពុងស្ថិតក្នុងភាពមិនប្រាកដប្រជាជាច្រើនយ៉ាងណាក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជានៅតែអាចបន្តកំណើនខ្ពស់និងរឹងមាំ ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខនេះ។ ជាក់ស្ដែង ក្នុងឆ្នាំ ២០១៧ កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា ៦,៨% ដែលការណ៍នេះជាកាលានុវត្តភាពល្អ សម្រាប់ប្រទេសកម្ពុជា ក្នុងការស្រូបទាញយកនូវសក្ដានុពលនៃទីផ្សារអាកាសចរពិភពលោកក្នុងការធ្វើឱ្យកាន់តែមានការរីកចម្រើនបន្ថែមទៀត ដូចដែលរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកំពុងអនុវត្តរាល់ថ្ងៃ ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និបាតទាំងមូលជាទីមេត្រី!*

១០. នាពេលបច្ចុប្បន្ននេះ វិស័យអាកាសចរស៊ីវិល ជាវិស័យមួយដែលកំពុងមានភាពទាក់ទាញ និងរីកចម្រើនប្រកបដោយសក្តានុពល ដែលជាផ្នែកដ៏សំខាន់មួយមិនអាចខ្វះបាននៃសេដ្ឋកិច្ចពិភពលោក ដែលកាន់តែមានលក្ខណៈជាសាកល តាមរយៈការជួយសម្រួលពាណិជ្ជកម្មអន្តរជាតិ ទេសចរណ៍ និងវិនិយោគទុនអន្តរជាតិ ព្រមទាំងជួយភ្ជាប់ប្រជាជនពីទ្វីបមួយទៅទ្វីបមួយទៀតនៅទូទាំងពិភពលោក។

១១. ជាមួយគ្នានេះដែរ នៅក្នុងរបាយការណ៍របស់ ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** ក៏បានលើកឡើងផងដែរថា « *វិស័យអាកាសចរណ៍ជាឧស្សាហកម្មដែលកំពុងតែរីកលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងពិភពលោក និងតំបន់ ដែលត្រូវបានគេចាត់ទុកថា ជាកត្តាយុទ្ធសាស្ត្រនៃផលិតកម្ម និងជាស្នូលនៃដំណើរការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ*»។ ក្នុងន័យនេះ ដើម្បីឱ្យវិស័យអាកាសចរស៊ីវិលនៅតែបន្តជួយជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ នៅកម្ពុជាបន្តទៀត ខ្ញុំស្នើសុំអង្គសន្និបាតនៅពេលនេះ យកចិត្តទុកដាក់ផ្លាស់ប្តូរគំនិត ពិគ្រោះយោបល់គ្នា រិះរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាដែលយើងជួបប្រទះក្នុងពេលបំពេញភារកិច្ច ជាពិសេស ត្រូវយកចិត្តទុកដាក់លើបញ្ហាមួយចំនួន ដូចខាងក្រោមនេះ៖

**ក) ការកែទម្រង់ស្ថាប័ន៖**

- ត្រូវកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋលេខាធិការដ្ឋានឱ្យបានសមស្រប ដើម្បីឆ្លើយតបទៅនឹងតម្រូវការការងារផង និងសម្របទៅនឹងនិន្នាការទូទៅ ក៏ដូចជាការវិវត្តវិស័យអាកាសចរស៊ីវិលអន្តរជាតិផង។
- ត្រូវពង្រឹងសាមគ្គីភាព កិច្ចសហការផ្ទៃក្នុង និងស្មារតីការងារជាក្រុម។
- កែសម្រួលផ្នត់គំនិត និងឥរិយាបថការងារ ដោយការយកសមភាព តម្លាភាព សមត្ថភាព និងតម្កល់ផលប្រយោជន៍រួមជាធំ។

**ខ) បញ្ហាសុវត្ថិភាព-សន្តិសុខអាកាសចរណ៍៖**

- ត្រូវយកចិត្តទុកដាក់ដោះស្រាយចំណុចខ្វះខាតនានា ដែលអង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) បានរកឃើញ ក្នុងពេលចុះមកធ្វើសវនកម្មនៅកម្ពុជា

នាពេលកន្លងមក ទាំងផ្នែកសន្តិសុខ និងផ្នែកសុវត្ថិភាពអាកាសចរណ៍ ដើម្បីជៀសឱ្យផុតពីការដាក់កម្ពុជាទៅក្នុងបញ្ជីខ្មៅ (Black list)។

- យកចិត្តទុកដាក់ក្នុងការរៀបចំ និងកែសម្រួលបទប្បញ្ញត្តិបច្ចេកទេសអាកាសចរ និងឯកសារណែនាំអនុវត្តនានា ឱ្យស្របតាមស្តង់ដាអប្បរិមារបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)។

**ខ) ការបណ្តុះបណ្តាលធនធានមនុស្ស៖**

- ត្រូវយកចិត្តទុកដាក់លើកកម្ពស់កម្រិតវិជ្ជាជីវៈមន្ត្រីបច្ចេកទេសឱ្យកាន់តែខ្ពស់ស្របតាមតម្រូវការស្តង់ដាអន្តរជាតិ។
- ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលឱ្យបានសមស្រប ជាពិសេសយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលមន្ត្រីបន្តវេនជាយុវជនដែលមានសក្តានុពល។
- ត្រូវស្វែងរកកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកឱកាសបណ្តុះបណ្តាលជំនាញជូនមន្ត្រីទៅតាមសមត្ថភាព និងសក្តានុពលរបស់ខ្លួន ទាំងក្នុង និងក្រៅប្រទេស។

**១២.** ខ្ញុំសង្ឃឹមថា សន្និបាតរយៈពេលពីរថ្ងៃនេះ នឹងផ្តល់ឱកាសគ្រប់គ្រាន់ដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងអ្នកពាក់ព័ន្ធបានពិនិត្យពិភាក្សា និងវាយតម្លៃលើលទ្ធផលការងារ និងស្វែងរកជម្រើសដ៏ប្រសើរក្នុងការកំណត់ទិសដៅការងារ និងផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៨ ក៏ដូចជាឆ្នាំបន្តបន្ទាប់ទៀត។

**១៣.** ជាថ្មីម្តងទៀត ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការធ្វើឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត នៅក្នុងវិស័យអាកាសចរស៊ីវិល នាពេលកន្លងមកនេះ ជាពិសេស ខ្ញុំសូមស្នើដល់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ បន្តពង្រឹងនូវកិច្ចសហការណ៍ក្នុងភាពជាដៃគូកម្រិតជំនាញជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបន្ថែមទៀត ដើម្បីជំរុញឱ្យវិស័យនេះកាន់តែមានការរីកចម្រើនប្រសើរឡើង។

**១៤.** ជាទីបញ្ចប់ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ទាំងអស់ សូមប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និង

សូមឱ្យអង្គសន្និបាតទាំងមូលប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ និងទទួលបានលទ្ធផលជាផ្លែផ្កា។

**១៥.** ខ្ញុំសូមប្រកាសបើក «សន្និបាតបូកសរុបលទ្ធផលការងារអាកាសចរស៊ីវិល ឆ្នាំ២០១៣-២០១៧ និងលើកទិសដៅសម្រាប់ឆ្នាំ២០១៨-២០២៣» ចាប់ពីពេលនេះតទៅ៕

**សូមអរគុណ!**